ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបាត់ដំបង**
**ការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម**

# របាយការណ៍
# ស្តីពី ការបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៧

## ១ ស្ថានភាពរួម

ការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបាត់ដំបងបានបំពេញការងារក្នុងតួនាទីជាភ្នាក់ងារសម្របសម្រួលក្នុងការបង្កើត និងជំរុញសហគមន៍កសិកម្ម ដែលបច្ចុប្បន្នសហគមន៍កសិកម្ម ក្នុងខេត្តបាត់ដំបងមានចំនួន ៨៥សហគមន៍ ស្ថិតនៅតាមបណ្ដាស្រុក-ក្រុងទាំង ១៤ ។ ក្រៅពីការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្មជាអ្នកសម្របសម្រួល និងត្រួតពិនិត្យតាមដានដល់សហគមន៍កសិកម្មក៏មានអង្គការដៃគូអភិវឌ្ឍន៍នានាដែលបាននឹងកំពុងគាំទ្រដល់ការអភិវឌ្ឍន៍សហគមន៍កសិកម្មផងដែរ។ បណ្ដាអង្គការទាំងនោះរួមមាន៖ អង្គការទស្សនៈពិភពលោក, អង្គការការីតាស, អង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍, អង្គការក្រុមអភិវឌ្ឍន៍ភូមិ, សមាគមដើម្បីអភិវឌ្ឍន៍សហគមន៍ខ្មែរជាដើម ។

ជាទូទៅសហគមន៍កសិកម្មមានមុខរបរចម្បងលើសេវាកម្មឥណទាន ដោយផ្ដល់ប្រាក់កម្ចី និងទទួលប្រាក់សន្សំសម្រាប់សមាជិក។ មុខរបរសំខាន់មួយចំនួនទៀតដែលសហគមន៍កសិកម្មកំពុងដំណើរការរួមមាន៖ ផ្គត់ផ្គង់ធាតុចូលកសិកម្ម, ទីផ្សារកសិផល, ផលិតកម្មដំណាំនិងសត្វ, ផលិតពូជស្រូវ, ឡសម្ងួតស្រូវ, លក់ប្រេងឥន្ធនៈ និងលក់គ្រឿងបរិភោគជាដើម។

## ២ ស្ថានភាពបុគ្គលិក

មន្ត្រីបំពេញការងារនៅការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្មមានចំនួន ១៣នាក់ ស្រីចំនួន ០២នាក់ ក្នុងនោះមានមន្ត្រីចំនួន ០៣នាក់ត្រូវបានបែងចែកឲ្យទៅប្រចាំការនៅស្រុកមោងឫស្សី ០១នាក់, ស្រុកថ្មគោល ០១នាក់, និងស្រុកបវេល ០១នាក់ ។ មន្ត្រីការិយាល័យទាំងអស់មានប្រភេទក្របខណ្ឌ និងកម្រិតបណ្ដុះបណ្ដាលខាងក្រោម៖

- ប្រភេទក្របខណ្ឌ(ក)ចំនួន ០២នាក់, ក្របខណ្ឌ(ខ)ចំនួន ០៣នាក់, និងក្របខណ្ឌ(គ)ចំនួន ០៨នាក់,
- ថ្នាក់អនុបណ្ឌិតចំនួន០២នាក់, ថ្នាក់បរិញ្ញាបត្រចំនួន ០៥នាក់, ថ្នាក់មធ្យមចំនួន ០២នាក់, និងថ្នាក់បឋមចំនួន ០៤នាក់ ។

ការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម ក៏បានសហការជាមួយការិយាល័យកសិកម្មស្រុកទាំង១៣ និងក្រុង១ ដើម្បីរួមគ្នាជួយអភិវឌ្ឍសហគមន៍កសិកម្មតាមបណ្ដាលស្រុក និងក្រុងផងដែរ ។

## ៣ សកម្មភាព និង លទ្ធផលសម្រេចបាន

### ក ការរៀបចំពិធីចែកវិញ្ញាបនបត្រទទួលស្គាល់សហគមន៍កសិកម្ម

ការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម បានរៀបចំពិធីចែកវិញ្ញាបនបត្រទទួលស្គាល់សហគមន៍កសិកម្មគំរូថ្មីជូនដល់សហគមន៍កសិកម្មទាំង ៧៨សហគមន៍ក្នុងខេត្តបាត់ដំបងដោយទទួលបានការឧបត្ថម្ភពីអង្គការទស្សនពិភពលោកអន្តរជាតិកម្ពុជាប្រចាំខេត្តបាត់ដំបង ដែលមានអ្នកចូលរួមសរុបចំនួន ៩០នាក់ ស្រី ២២នាក់ ។

### ខ ការចុះបញ្ជីទទួលស្គាល់សហគមន៍កសិកម្ម

- បានចុះបញ្ជីទទួលស្គាល់សហគមន៍កសិកម្មថ្មីចំនួន ១០សហគមន៍ដូចខាងក្រោម៖

| ល.រ | ឈ្មោះសហគមន៍ | ទីកន្លែង | លេខចុះបញ្ជី និងកាលបរិច្ឆេទ | សមាជិកសរុប | ចំនួនហ៊ុន | ដើមទុន (រៀល) |
|---|---|---|---|---|---|---|
| ១ | សហគមន៍កសិកម្ម ខាំ-កូគីឡូ៣៨ | ភូមិគីឡូ៣៨ ឃុំព្រែង ស្រុករតនមណ្ឌល | ០៧៨ សក.បប/សកក ១០/០២/២០១៧ | ៥១នាក់ ស្រី ១៥នាក់ | ៦១ | ៦,១០០,០០០ (១០០,០០០/ហ៊ុន) |
| ២ | សហគមន៍កសិកម្ម គ្រួសរុងរឿង | ភូមិគ្រួស ឃុំអន្លង់វុន ស្រុកថ្មគោល | ០៧៩ សក.បប/សកក ២០/០៦/២០១៧ | ៧៦នាក់ ស្រី ៦១នាក់ | ២៧៩ | ២,៧៩០,០០០ (១០,០០០/ហ៊ុន) |
| ៣ | សហគមន៍កសិកម្ម ទន្លេត្រីមាស | ភូមិបាក់ព្រា ឃុំព្រៃចាស់ ស្រុកឯកភ្នំ | ០៨០ សក.បប/សកក ២០/០៦/២០១៧ | ៧៨នាក់ ស្រី៤៨នាក់ | ១២១ | ៦,០៥០,០០០ (៥០,០០០/ហ៊ុន) |
| ៤ | សហគមន៍កសិកម្ម កោះជីវាំងអភិវឌ្ឍន៍ថ្មី | ភូមិអន្លង់តាអួរ ឃុំកោះជីវាំង ស្រុកឯកភ្នំ | ០៨១ សក.បប/សកក ២០/០៦/២០១៧ | ៩៣នាក់ ស្រី ៥៧នាក់ | ៩៧ | ៤,៨៥០,០០០ (៥០,០០០/ហ៊ុន) |
| ៥ | សហគមន៍កសិកម្ម សម្បត្តិមូលដ្ឋាន | ភូមិខ្នាចរមាស ឃុំខ្នាចរមាស ស្រុកបវេល | ០៨២ សក.បប/សកក ០១/០៨/២០១៧ | ១២៨នាក់ ស្រី ៧៨នាក់ | ៦៣៧ | ១២,៧៤០,០០០ (២០,០០០/ហ៊ុន) |
| ៦ | សហគមន៍កសិកម្ម ស្ទឹកសង្កែ | ភូមិអន្លង់តាម៉ី ឃុំឈើទាល ស្រុកបាណន់ | ០៨៣ សក.បប/សកក ២០/០៦/២០១៧ | ៧៨នាក់ ស្រី៤៨នាក់ | ២៤២ | ៩,៩១៤,០០០ (៤០,០០០/ហ៊ុន) |
| ៧ | សហគមន៍កសិកម្ម សាមគ្គី | ភូមិហៃសាន ឃុំជ្រៃ ស្រុថ្មគោល | ០៨៤ សក.បប/សកក ២១/០៨/២០១៧ | ១០៩នាក់ ស្រី ៧៣នាក់ | ៣៩៣.៥ | ៧,៨៧០,០០០ (២០,០០០/ហ៊ុន) |
| ៨ | សហគមន៍កសិកម្ម បាណន់ | ភូមិចំការអូរ ឃុំកន្ទឺ២ ស្រុកបាណន់ | ០៨៥ សក.បប/សកក ២៣/០៨/២០១៧ | ១២៥នាក់ ស្រី ៥២នាក់ | ១២៥ | ២,៥០០,០០០ (២០,០០០/ហ៊ុន) |
| ៩ | សហគមន៍កសិកម្ម អាងកំពីងពួយ | ភូមិអន្លង់ស្វាយ ឃុំតាគ្រាម | ០៨៦ សក.បប/សកក | ៥៨នាក់ ស្រី ១៤នាក់ | ៦០ | ៣,០០០,០០០ (៥០,០០០/ហ៊ុន) |

| | | | | | | |
|---|---|---|---|---|---|---|
| | | ស្រុកបាណន់ | ១៤/០៩/២០១៧ | | | |
| ១០ | សហគមន៍កសិកម្ម តាសីសាមគ្គី | ភូមិតាសី ឃុំតាម៉ឺន ស្រុកថ្មគោល | ០៨៧ សក.បប/សកក ១៤/០៩/២០១៧ | ៦២នាក់ ស្រី ២៤នាក់ | ១៥៥ | ៧,៧៥០,០០០ (៥០,០០០/ហ៊ុន) |

- បានកំពុងរៀបចំឯកសារសហគមន៍កសិកម្មថ្មីសម្រាប់ចុះបញ្ជីទទួលស្គាល់ចំនួន ២ទៀតគឺៈ
  - សហគមន៍កសិកម្មបាត់ដំបងមានជ័យ ស្ថិតនៅភូមិកំពង់ឆ្លង ឃុំវត្តតាមិម ស្រុកសង្កែ
  - សហគមន៍កសិកម្មកៅស៊ូគ្រួសារស្រុកសំឡូត នៅភូមិព្រៃរំចេក ឃុំតាសាញ ស្រុកសំឡូត ។

**គ ការលុបឈ្មោះសហគមន៍កសិកម្ម**

ការិយាល័យបានសម្រេចលុបចោលសហគមន៍កសិកម្មចំនួន ២សហគមន៍ដែលមិនមានដំណើរការស្របតាមមាត្រា៦៤ និង១០៩ នៃច្បាប់សហគមន៍កសិកម្ម រួមមានៈ

សហគមន៍កសិកម្មមង្គល ស្ថិតនៅភូមិរបស់មង្គល ឃុំរបស់មង្គល ស្រុកមោងឫស្សី

សហគមន៍កសិកម្មផលមានជ័យ ស្ថិតនៅភូមិបល្ល័ង្គមានជ័យ ឃុំខ្នាចរមាស ស្រុកបវេល ។

**ឃ ការផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់សហគមន៍កសិកម្ម**

ការផ្សព្វផ្សាយដល់កសិករ

| ប្រធាបទ | ចំនួនលើក | អ្នកចូលរួម | | ទីកន្លែង |
|---|---|---|---|---|
| | | សរុប | ស្រី | |
| 1. ច្បាប់សហគមន៍កសិកម្ម | ១២ | ៥១៣ | ២២០ | - ភូមិគីឡូ៣៨ ឃុំត្រែង ស្រុករតនមណ្ឌល,<br>- ភូមិគ្រួស ឃុំអន្លង់រុន, ភូមិហៃសាន ឃុំជ្រៃ និងភូមិតាសី ឃុំតាម៉ឺន ស្រុកថ្មគោល<br>- ភូមិបាក់ព្រា ឃុំព្រៃចាស់ និងភូមិ អន្លង់តាអួរ ឃុំកោះជីវាំង ស្រុកឯកភ្នំ,<br>- ភូមិខ្នាចរមាស ឃុំខ្នាចរមាស ស្រុកបវេល,<br>- ភូមិអន្លង់ស្វាយ ឃុំតាគ្រាម, ភូមិចំការអួរ ឃុំកន្ទឺ២ និងភូមិអន្លង់តាមី ឃុំឈើទាល ស្រុកបាណន់<br>- ភូមិកំពង់ឆ្លង ឃុំវត្តតាមិម ស្រុកសង្កែ |
| 2. លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងគំរូសម្រាប់សហគមន៍កសិកម្ម | ១២ | ៥០៣ | ២៤៣ | |
| 3. លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងគំរូសហភាពសហគមន៍កសិកម្ម | ០១ | ៣០ | ០៤ | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មកពីសហគមន៍កសិកម្មឃុំកំពង់ព្រៀង, ចម្រើនផល វាំងកេសី, ភ្នំក្រពើ, និងពន្លឺថ្មីក្តីសង្ឃឹមនៃកសិករ |

ការបណ្តុះបណ្តាលដល់សហគមន៍កសិកម្ម

| ប្រធានបទ | ចំនួនវគ្គ | ចំនួនសហគមន៍ | អ្នកចូលរួម | | ស្ថាប័ន/ គម្រោង |
|---|---|---|---|---|---|
| | | | សរុប | ស្រី | |
| 1. ភាពជាអ្នកដឹកនាំ និងគ្រប់គ្រងសហគមន៍កសិកម្ម | 3 | 20 | 108 | 30 | ជំរុញផលិតកម្មស្បៀង |
| | 5 | 50 | 200 | 61 | ថវិកាកម្មវិធី |

| | | | | | |
|---|---|---|---|---|---|
| 2. ការចុះបញ្ជីគណនេយ្យ | 3 | 3 | 26 | 8 | RICE-SDP |
| 3. ទីផ្សារកសិផល | 1 | 10 | 52 | 18 | ASPIRE |
| 4. ផលិតកម្មគ្រាប់ពូជ | 2 | 6 | 54 | 12 | RIAPIP |
| 5. ផែនការសកម្មភាពប្រចាំឆ្នាំសម្រាប់សហគមន៍កសិកម្ម | 3 | 23 | 72 | 26 | ពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ |
| 6. ផែនការអាជីវកម្មសម្រាប់សហគមន៍កសិកម្ម | 2 | 16 | 76 | 28 | ពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ |
| | 1 | 10 | 52 | 18 | ASPIRE |
| 7. សវនកម្មដោយគណៈកម្មាធិការត្រួតពិនិត្យសហគមន៍កសិកម្ម | 2 | 10 | 25 | 7 | ពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ |
| 8. សហគ្រិនភាព | 1 | 11 | 54 | 17 | ASPIRE |

### ង ការចូលរួមមហាសន្និបាតរបស់សហគមន៍កសិកម្ម

បានចូលរួម និងសម្របសម្រួលមហាសន្និបាតរបស់សហគមន៍កសិកម្មចំនួន ២២លើករួមមាន ៖ សហគមន៍កសិកម្មមានជ័យរស្មីរុងរឿង, ទឹកចិត្តកសិករគារមានជ័យ, ខាំ-កូគីឡូ៣៨, ពន្លឺថ្មីសាមគ្គី, រំដួលភ្នំព្រឹក, គ្រួសរុងរឿង, សង្ហាផល, ច្រនៀងចែង៣សចម្រើនផល, ពន្លឺថ្មីក្តីសង្ឃឹមនៃកសិករ, កសិករញញឹម, ទន្លេត្រីមាស, កោះជីវាំងអភិវឌ្ឍន៍ថ្មី, សម្បត្តិមូលដ្ឋាន, ស្ទឹងសង្កែ, សាមគ្គី, អាងកំពីងពួយ, តាសីសាមគ្គី, ពន្លឺស្រ្តី, ស្វាយជ្រុំជុំរុំផល, បាត់ដំបងមានជ័យ, កៅស៊ូគ្រួសារស្រុកសំឡូត, ។

### ច ការដោះស្រាយវិវាទ

បានសម្របសម្រួលដោះស្រាយវិវាទសហគមន៍កសិកម្មបានចំនួន ២លើកគឺ៖

- សហគមន៍កសិកម្មត្រែងជោគជ័យរស្មីផ្លូវមាស៖ បានសម្របសម្រួលដោះស្រាយវិវាទរវាងសហគមន៍កសិកម្មជាមួយនឹងក្រុមហ៊ុនជេ ស៊ី ហ្វូដ ស្តីពីកិច្ចសន្យាលក់នៅឆ្នាំ២០១៤។
- សហគមន៍កសិកម្មពន្លឺថ្មីពេជ្រចិន្តា៖ បានសម្របសម្រួលដោះស្រាយវិវាទរវាងសហគមន៍កសិកម្មជាមួយអតីតបេឡាករ ដែលរងការចោទធ្វើឲ្យបាត់ប្រាក់សរុបចំនួន ៤១,០៥៥,៧០០រៀល កាលពីឆ្នាំ២០១៥ ។

### ឆ ការជូនសហគមន៍កសិកម្ម និងកសិករប្រលងប្រណាំងថ្នាក់ជាតិប្រចាំឆ្នាំ

បានបញ្ជូនតំណាងសហគមន៍កសិកម្មចំនួន ០១នាក់ និង និងកសិករឆ្នើម ០១នាក់ចូលរួមប្រលងប្រណាំងថ្នាក់ជាតិប្រចាំឆ្នាំនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយទទួលបានចំណាត់ថ្នាក់លេខ ៣ លើផ្នែក៖

- អ្នកស្រី លី ធឿត កសិកររស់នៅភូមិតាស៊ង ឃុំបាយដំរាំ ស្រុកបាណន់ទទួលបានលេខ ៣ លើប្រធានបទផលិតកម្មស្រូវដោយប្រើប្រាស់គ្រាប់ពូជមានគុណភាពល្អនិងបច្ចេកទេសទំនើបសម្រាប់ធ្វើពាណិជ្ជកម្ម
- លោក សេន ចាន់ថូ ប្រធានសហគមន៍កសិកម្មកសិកម្មញញឹម ស្ថិតនៅឃុំរស្មីសង្ហា ស្រុករតនមណ្ឌល ទទួលបានលេខ ៣ ក្នុងការប្រលងប្រជែងលើប្រធានបទ ភាពជោគជ័យនៃការដឹកនាំ និងគ្រប់គ្រងសហគមន៍កសិកម្ម។

### ជ ការចូលរួមតាំងពិព័រណ៍បន្ទាញ

ការិយាល័យបានសម្របសម្រួលឲ្យសហគមន៍ចូលរួមតាំងពិព័រណ៍ផលិតផលរបស់ខ្លួនក្នុងកម្មវិធីសំខាន់ៗ ដូចខាងក្រោម៖

| ល.រ | ប្រធានបទពិព័រណ៍ | ចំនួនសហគមន៍ | ស្ថាប័ន/ គម្រោងអ្នករៀបចំ | ទីកន្លែង | ពេលវេលា |
|---|---|---|---|---|---|
| 1 | ពិព័រណ៍ពាណិជ្ជកម្មផលិតផលខ្មែរ | ៣ | ក្រសួងពាណិជ្ជកម្ម | បាត់ដំបង | ២៥-២៨ ឧសភា |
| 2 | ពិព័រណ៍ពាណិជ្ជកម្មផលិតផលខ្មែរ | ៤ | ក្រសួងពាណិជ្ជកម្ម | ប៉ៃលិន | ៧-១០ វិច្ឆិកា |
| 3 | ពិព័រណ៍ផ្សារណាត់បន្លែសុវត្ថិភាព និងផលិតផលសុវត្ថិភាព | ៩ | គម្រោងជំរុញផលិតកម្មស្បៀង | បាត់ដំបង | ១៤ ធ្នូ |

## ឈ ការពង្រឹងសមត្ថភាពដល់មន្ត្រី/ សិក្ខាសាលា /ទស្សនកិច្ចសិក្សា

ការពង្រឹងសមត្ថភាពដល់មន្ត្រី

| ប្រធានបទ | រយៈពេល | ចំនួនមន្ត្រី | ស្ថាប័ន/ គម្រោង |
|---|---|---|---|
| 1. ភាពជាអ្នកដឹកនាំ និងគ្រប់គ្រងសហគមន៍កសិកម្ម | ២ថ្ងៃ | ២ | ជំរុញផលិតកម្មស្បៀង |
| 2. ការគ្រប់គ្រងនិងប្រើប្រាស់ទឹកប្រកបដោយប្រសិទ្ធភាពសម្រាប់ដំណាំ | ១ថ្ងៃ | ៤ | កម្មវិធីស្នូលគាំទ្រវិស័យកសិកម្មក្នុងមហាអនុតំបន់មេគង្គជំហាន២ |
| 3. ស្តង់ដារកម្ពុជាសម្រាប់អង្ករផ្ការំដួល និងផ្កាច័ន្ទសែនសរ | ១ថ្ងៃ | ១ | វិទ្យាស្ថានស្តង់ដារកម្ពុជា |
| 4. ការប្រើប្រាស់កម្មវិធីប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) | ៥ថ្ងៃ | ៣ | កម្មវិធីជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ (RICE-SDP) |
| 5. ការត្រួតពិនិត្យផ្ទៃក្នុងរបស់សហគមន៍កសិកម្ម | ២ថ្ងៃ | ៣ | នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម |
| 6. ការរៀបចំទម្រង់ P3 និង P4 | ៣ថ្ងៃ | ២ | ASPIRE |
| 7. ការរៀបចំទម្រង់ M&E ដើម្បីតាមដានផែនការសកម្មភាពថវិកា | ៣ថ្ងៃ | ២ | ASPIRE |
| 8. ច្បាប់សហគមន៍កសិកម្ម | ១ថ្ងៃ | ៣ | ការិយាល័យនិតិកម្មនិងដោះស្រាយ វិវាទសហគមន៍កសិកម្ម |
| 9. បែបបទបច្ចេកទេស និងនីតិវិធីក្នុងការរៀបចំផែនការសកម្មភាព ការរៀបចំថវិកា ការតាមដាន និងវាយតម្លៃ ក្នុងក្របខ័ណ្ឌថវិកាកម្មវិធី | ៣ថ្ងៃ | ២ | ថវិកាកម្មវិធី |
| 10. គោលការណ៍ណែនាំនៃការគ្រប់គ្រងមុខរបរឥណទានសហគមន៍កសិកម្ម | ២ថ្ងៃ | ២ | នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម |

សិក្ខាសាលា

| ប្រធានបទ | ចំនួនមន្ត្រី | ស្ថាប័ន/គម្រោង |
|---|---|---|
| 1. ប្រព័ន្ធព័ត៌មានទីផ្សារស្រូវអង្ករ | ៣ | VSO |
| 2. កិច្ចអភិវឌ្ឍសហគមន៍កសិកម្មនៅកម្ពុជាជាមួយភ្នាក់ងារអភិវឌ្ឍន៍សហគមន៍កសិកម្ម | ១ | នាយកដ្ឋានអភិវឌ្ឍន៍ សហគមន៍កសិកម្ម |
| 3. ការអនុវត្តល្អ និងលទ្ធផលរបស់គម្រោងបង្កើនប្រាក់ចំណូល និងអាហារូបត្ថម្ភតាមរយៈការពង្រឹងសិទ្ធិជាម្ចាស់ដល់សហគមន៍ | ១ | សមាគមអភិវឌ្ឍន៍សហគមន៍ខ្មែរ និង HEIFER |
| 4. ការសិក្សាពីផលប៉ះពាល់នៃការកែច្នៃដំណាំដំឡូងមី និងវិធានការកាត់បន្ថយហានិភ័យ និង កិច្ចប្រជុំពិនិត្យលើការធ្វើបច្ចុប្បន្នភាពសមាគមដំឡូងមី | ១ | មន្ទីរពាណិជ្ជកម្ម |
| 5. នីតិវិធីបង្កើត និងចុះបញ្ជីសហគមន៍កសិកម្ម | ១ | នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម |
| 6. ការកសាងផែនការយុទ្ធសាស្ត្រសម្រាប់សហភាពសហគមន៍កសិកម្ម | ២ | ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |
| 7. លទ្ធផលនៃការអនុវត្តគម្រោងលើកស្ទួយសហគមន៍កសិកម្មនៅកម្ពុជាសម្រាប់ ខេត្តបាត់ដំបង បន្ទាយមានជ័យ និងប៉ៃលិនឆ្នាំ២០១៥-២០១៧ | ១ | ពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ |

ទស្សនកិច្ចសិក្សាសហគមន៍កសិកម្ម

| គោលបំណង | ចំនួនមន្ត្រី | ទីកន្លែង | ស្ថាប័ន/គម្រោង |
|---|---|---|---|
| 1. ការគ្រប់គ្រងសហគមន៍កសិកម្ម | ០៤ | ប៉ៃលិន | នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម |
| 2. ការបង្កើតនិងអភិវឌ្ឍន៍សហភាពសហគមន៍កសិកម្ម, ការធ្វើកិច្ចសន្យាកសិកម្មក្នុងការផលិតស្រូវសុវត្ថិភាព និងស្រូវសរីរាង្គ | ០២ | ព្រះវិហារ | VSO |
| 3. ការគ្រប់គ្រងសហគមន៍កសិកម្ម | ០១ | វៀតណាម | អង្គការជីវិតថ្លៃថ្នូរ (LWD) |
| 4. ដំណើរការសហភាពសហគមន៍កសិកម្ម | ០១ | ព្រះវិហារ | ពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ |
| 5. ក្រុមកសិករផលិតបន្លែសរីរាង្គ និងទីផ្សារកសិផលសរីរាង្គរបស់អង្គការសេដាក | ០១ | កណ្ដាល, កំពង់ស្ពឺ, ភ្នំពេញ | ទស្សនពិភពលោកអន្តរជាតិកម្ពុជា WVC |

## ៧ ការចងក្រងក្រុមកសិករ

បានចុះរៀបចំចងក្រងក្រុមកសិករដាំបន្លែរបស់គម្រោងជំរុញផលិតកម្មស្មៀងចំនួន ៨ក្រុមដូចខាងក្រោមៈ

| ល.រ | ឈ្មោះក្រុមកសិករ | ទីកន្លែង | សមាជិក | |
|---|---|---|---|---|
| | | | សរុប | ស្រី |
| ១ | ក្រុមកសិករបន្លែសុវត្ថិភាពដៃមាសបបុះ | ភូមិបបុះ ឃុំឈើទាល ស្រុកបាណន់ | ១៥ | ០ |
| ២ | ក្រុមកសិករបន្លែសុវត្ថិភាពកំពីងពួយ | ភូមិអន្លង់ស្វាយ ឃុំតាក្រាម ស្រុកបាណន់ | ១៥ | ៣ |
| ៣ | ក្រុមកសិករបន្លែសុវត្ថិភាពចែងមានជ័យរស្មីកន្ទី១ | ភូមិទួលធ្នង់ ឃុំកន្ទី១ ស្រុកបាណន់ | ១៥ | ១ |
| ៤ | ក្រុមកសិករបន្លែសុវត្ថិភាពកំពង់ឆ្លងមានជ័យ | ភូមិកំពង់ឆ្លង ឃុំវត្តតាមិម ស្រុកសង្កែ | ១៥ | ៣ |
| ៥ | ក្រុមកសិករបន្លែសុវត្ថិភាពបឹងវែងរុងរឿង | ភូមិបឹងវែង ឃុំរាំងកេសី ស្រុកសង្កែ | ១៥ | ៧ |
| ៦ | ក្រុមកសិករបន្លែសុវត្ថិភាពច្រនៀងមានឫទ្ធិ | ភូមិច្រនៀង ឃុំគោកឃ្មុំ ស្រុកថ្មគោល | ១៥ | ៣ |
| ៧ | ក្រុមកសិករបន្លែសុវត្ថិភាពភូមិតាសី | ភូមិតាសី ឃុំតាម៉ឺន ស្រុកថ្មគោល | ១៥ | ៤ |
| ៨ | ក្រុមកសិករបន្លែសុវត្ថិភាពតាសីអភិវឌ្ឍន៍កសិកម្ម | ភូមិតាសី ឃុំតាម៉ឺន ស្រុកថ្មគោល | ១៥ | ១ |

## ៨ ស្ថិតិសហគមន៍កសិកម្ម

តារាងសង្ខេបទិន្នន័យសហគមន៍កសិកម្មតាមស្រុក/ក្រុង

| ល.រ | ស្រុក/ក្រុង | ចំនួនសហគមន៍កសិកម្ម | សមាជិក | | អ្នកដឹកនាំ | | ដើមទុនបច្ចុប្បន្ន |
|---|---|---|---|---|---|---|---|
| | | | សរុប | ស្រី | សរុប | ស្រី | |
| 1 | ស្រុកមោងឫស្សី | 6 | 811 | 401 | 56 | 17 | 390,784,000 |
| 2 | ស្រុកភ្នំព្រឹក | 6 | 662 | 338 | 49 | 22 | 885,694,300 |
| 3 | ស្រុកកំរៀង | 5 | 838 | 414 | 40 | 16 | 766,056,760 |
| 4 | ស្រុកសំពៅលូន | 6 | 744 | 477 | 44 | 18 | 1,069,527,920 |
| 5 | ស្រុកគាស់ក្រឡ | 8 | 1,334 | 720 | 76 | 24 | 447,917,200 |
| 6 | ស្រុកសង្កែ | 6 | 692 | 291 | 51 | 13 | 356,619,180 |
| 7 | ស្រុកថ្មគោល | 9 | 597 | 344 | 62 | 20 | 118,954,740 |
| 8 | ស្រុកបវេល | 6 | 1,014 | 479 | 51 | 22 | 603,847,680 |
| 9 | ស្រុកបាណន់ | 11 | 1,690 | 963 | 85 | 26 | 1,319,016,720 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 10 | ក្រុងបាត់ដំបង | 2 | 152 | 123 | 13 | 8 | 60,926,000 |
| 11 | ស្រុកឯកភ្នំ | 4 | 415 | 252 | 32 | 12 | 111,280,609 |
| 12 | ស្រុករតនមណ្ឌល | 6 | 685 | 352 | 59 | 17 | 415,710,050 |
| 13 | ស្រុកសំឡូត | 6 | 1,762 | 1,200 | 65 | 29 | 904,299,620 |
| 14 | ស្រុករុក្ខគិរី | 4 | 314 | 204 | 34 | 16 | 86,980,500 |
| | សរុប | **85** | **11,710** | **6,558** | **717** | **260** | **7,537,615,279** |

**ដ្យាក្រាមទី ១ ចំនួនសហគមន៍កសិកម្មផ្អែកតាមទំហំទ្រព្យសកម្មសរុប**




**ដ្យាក្រាមទី ២ ចំនួនសហគមន៍កសិកម្មផ្អែកតាមប្រភេទទ្រព្យសម្បត្តិ**



### ដ្យាក្រាមទី ៣ ចំនួនសហគមន៍កសិកម្មផ្អែកតាមភាពដំណើរការមុខរបរ




### ដ្យាក្រាមទី ៤ ចំនួនសហគមន៍កសិកម្មផ្អែកតាមប្រភេទមុខរបរ




## ៤ បញ្ហាប្រឈម

- សមត្ថភាពថ្នាក់ដឹកនាំសហគមន៍ក្នុងការកត់ត្រាបញ្ជីគណនេយ្យនៅមានកម្រិតទាប
- អ្នកដឹកនាំសហគមន៍កសិកម្មមួយចំនួនអសកម្ម
- សហគមន៍កសិកម្មភាគច្រើនមិនទាន់ធ្វើមហាសន្និបាតប្រចាំឆ្នាំ និងរបាយការណ៍ប្រចាំឆ្នាំ
- សហគមន៍កសិកម្មខ្លះមានបញ្ហាលើដើមទុន ដោយសមាជិកខ្ជិលសងសហគមន៍។

## ៥ ទិសដៅបន្ត

- ចុះបញ្ជីសហគមន៍កសិកម្មថ្មីចំនួន២
- ចូលរួមមហាសន្និបាតសហគមន៍កសិកម្ម
- ជំរុញការរៀបចំមហាសន្និបាត សហគមន៍កសិកម្មប្រចាំឆ្នាំ
- ជំរុញការរៀបចំរបាយការណ៍ប្រចាំឆ្នាំ របស់សហគមន៍កសិកម្ម

- ជួយអន្តរាគមន៍ដល់សហគមន៍កសិកម្មដែលជួបបញ្ហាត្រូវដោះស្រាយ
- ពង្រឹង និងតាមដានសកម្មភាពសហគមន៍កសិកម្ម
- ជួយអន្តរាគមន៍ដល់សហគមន៍ កសិកម្មដែលជួបបញ្ហា
- បន្តសហការនឹងអង្គការ និងគម្រោងនានា
- បណ្តុះបណ្តាលវគ្គផែនការអាជីវកម្មដល់សហគមន៍កសិកម្ម
- ធ្វើបច្ចុប្បន្នភាពទិន្នន័យរបស់សហគមន៍កសិកម្មបន្ត ។

ថ្ងៃពុធ ៣កើត ខែបុស្ស ឆ្នាំរកា ព.ស២៥៦១
បាត់ដំបង, ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៧
អ្នករៀបចំរបាយការណ៍

បានឃើញ និងឯកភាព
**ប្រធានការិយាល័យ**

ឆុំ សុភក្រ្តា

បានឃើញ និង ឯកភាព
ថ្ងៃ ខែបុស្ស ឆ្នាំរកា ព.ស២៥៦១
បាត់ដំបង,ថ្ងៃទី ខែ ធ្នូ ឆ្នាំ២០១៧
**ប្រ ធា ន ម ន្ទី រ**